ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៣៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច

## រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស

បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច សរសេរកាត់ **វ.ជ.ស** ។ **វ ជ ស** មានទីតាំងស្ថិតនៅផ្លូវជ្រោះងៀប ២ ភូមិដំណាក់ធំ ៣ សង្កាត់ ស្ទឹងមានជ័យ ខណ្ឌ មានជ័យ រាជធានីភ្នំពេញ។

## ជំពូកទី ២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

**វ ជ ស** មានបេសកកម្មបណ្តុះបណ្តាល និងស្រាវជ្រាវលើផ្នែកសង្គមកិច្ច ដោយភ្ជាប់ទៅនឹងតម្រូវការរបស់ប្រទេសជាតិ និងសង្គម។

**មាត្រា ៣.-**

**វ ជ ស** មានឋានៈស្មើអគ្គនាយកដ្ឋាន និងស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា ៤.-**

**វ.ជ.ស.** ដឹកនាំដោយនាយកមួយរូប និងនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។ ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ **វ.ជ.ស.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា ៥.-**

នាយក **វ.ជ.ស.** មានភារកិច្ចដូចខាងក្រោម៖

- បំពេញរាល់មុខងាររដ្ឋបាល និងគ្រប់គ្រងការងារទាំងឡាយ ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងបទបញ្ជាផ្ទៃក្នុងរបស់ **វ.ជ.ស.**
- អនុវត្តតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ក្នុងក្របខណ្ឌធានាឱ្យមានគុណភាព និងប្រសិទ្ធភាពនៃការងារបណ្តុះបណ្តាល
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍ **វ.ជ.ស.**
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ **វ ជ.ស.** ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

**មាត្រា ៦._**

**វ ជ ស** ធ្វើការបណ្តុះបណ្តាល កម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ លើមុខជំនាញសង្គមកិច្ច និងវិស្វកម្មឧបករណ៍សិប្បនិម្មិត និងរណប និងមានសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការគៀនឃ្លាំង និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការភ្នំពេញថ្មី សម្រាប់ធ្វើការបណ្តុះបណ្តាលក្រោមបរិញ្ញាបត្ររង។

**វ ជ ស** អាចបើកមហាវិទ្យាល័យ សាលា មជ្ឈមណ្ឌល សាខា មុខជំនាញ កម្រិត ឬប្រភេទបណ្តុះបណ្តាលផ្សេងៗទៀត ទៅតាមលទ្ធភាព និងការចាំបាច់ ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី ៣
## កម្មវិធីសិក្សា លក្ខខណ្ឌជ្រើសរើស និងការផ្តល់សញ្ញាបត្រ

**មាត្រា ៧._**

**វ.ជ.ស** ត្រូវរៀបចំកម្មវិធីសិក្សាលម្អិតតាមថ្នាក់ និងមុខជំនាញ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ ការជ្រើសរើសសាស្ត្រាចារ្យមកបង្រៀនត្រូវអនុលោម តាមគោលការណ៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៨._**

ការជ្រើសរើសនិស្សិតឱ្យចូលរៀននៅ **វ.ជ.ស.** ត្រូវស្របតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៩._**

និស្សិតដែលរៀនចប់តាមកម្មវិធីសិក្សា ក្រោមកម្រិតបរិញ្ញាបត្ររង និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សានៅ **វ.ជ.ស.** ត្រូវទទួលវិញ្ញាបនបត្រ ឬសញ្ញាបត្រ តាមមុខជំនាញដែលបានសិក្សា។ វិញ្ញាបនបត្រ ឬ សញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយ **វ.ជ.ស.** ហើយត្រូវទទួលស្គាល់ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

និស្សិតដែលរៀនចប់តាមកម្មវិធីសិក្សានៃកម្រិតបរិញ្ញាបត្ររង ឬបរិញ្ញាបត្រ និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សានៅ **វ.ជ.ស** ត្រូវទទួលបានសញ្ញាបត្របរិញ្ញាបត្ររង ឬ បរិញ្ញាបត្រ តាមមុខជំនាញដែលបានសិក្សា។ សញ្ញាបត្របរិញ្ញាបត្ររង ឬ បរិញ្ញាបត្រ ត្រូវផ្តល់ឱ្យដោយ **វ.ជ.ស.** ហើយត្រូវទទួលស្គាល់ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី ៤
## ប្រភពធនធាន

**មាត្រា ១០._**

**វ.ជ.ស** មានប្រភពធនធាន ដូចខាងក្រោម ៖

- ថវិកាជាតិដែលជាឧបសម្ព័ន្ធក្នុងកញ្ចប់ថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជ និងយុវនីតិសម្បទា

- ថវិកាដែលបានមកពីការបង់ថ្លៃសិក្សា
- ហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍនានា បរិច្ចាគរបស់សប្បុរសជន និងជំនួយឥតសំណង ឬកម្ចីដែលធ្វើឡើងតាមការយល់ព្រមពីរាជរដ្ឋាភិបាល។ **វ.ជ.ស.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀត ពីប្រភពក្នុង ឬក្រៅប្រទេស សម្រាប់បម្រើសេចក្តីត្រូវការក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

*ក្រសួងព្រះបរមរាជវាំង*
*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*អគ្គលេខាធិការរាជរដ្ឋាភិបាល*
*ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*ដូចមាត្រា ១២*
*រាជកិច្ច*
*ឯកសារ-កាលប្បវត្តិ*